ការកាត់ទោសមេដឹកនាំខ្មែរក្រហម

Khmer Rouge Trial Web Portal

# របាយការណ៍សង្ខេបមតិ
# នៃវិបផតថល
# ការកាត់ទោសមេដឹកនាំខ្មែរក្រហម

ចាប់ពីថ្ងៃទី១៩ ខែមករា

ដល់

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧

ដោយ : អង្គការខេមរិកានុនៅនៃកម្ពុជា

# បញ្ជីមាតិកា


បញ្ជីមាតិកា

បញ្ជីតារាង

បញ្ជីរូបភាព

១_ សាវតា---------------------------------------------------------------------------------------------- ១

គោលដៅ និងគោលបំណង ------------------------------------------------------------------- ២

វិធីស្រាវជ្រាវ--------------------------------------------------------------------------------- ៣

ទំហំគំរូ និងសំណៅ---------------------------------------------------------------------------- ៣

បញ្ហាប្រឈម------------------------------------------------------------------------------------ ៤

ផែនការនៃកម្រងសំណួរ ------------------------------------------------------------------------ ៤

មធ្យោបាយចូលទៅយកព័ត៌មាន-------------------------------------------------------------- ៥

២_ របកគំហើញពីការស្រាវជ្រាវ------------------------------------------------------------------ ៤

អ្នកអានវិបផតថលកាត់ទោសខ្មែរក្រហម -------------------------------------------------- ៤

អ្នកអានវិបផតថលមិនពាក់ព័ន្ធការកាត់ទោសខ្មែរក្រហម------------------------------------ ១២

៣_ សន្និដ្ឋាន និងអនុសាសន៍ --------------------------------------------------------------------- ១៥

សន្និដ្ឋាន---------------------------------------------------------------------------------------- ១៥

អនុសាសន៍-------------------------------------------------------------------------------------- ១៦

**ឯកសារភ្ជាប់ A.** កម្រងសំណួរសម្រាប់អ្នកឆ្លើយតបដែលស្វែងរកវិបផតថលកាត់ទោសខ្មែរក្រហម

**ឯកសារភ្ជាប់ B.** កម្រងសំណួរសម្រាប់អ្នកឆ្លើយតបដែលមិនស្វែងរកវិបផតថលកាត់ទោសខ្មែរក្រហម

# បញ្ជីតារាង


**តារាង១:** ប្រភពនៃការផ្សព្វផ្សាយវិបផតថលកាត់ទោសខ្មែរក្រហម------------------------------------------ ៥

**តារាង២:** អ្នកឆ្លើយតបចូលមើលព័ត៌មានព័ត៌មានកាត់ទោសខ្មែរក្រហម------------------------------------ ៦

**តារាង៣:** ចំនួនដងនៃការស្វែងរកព័ត៌មានតាមរយៈវិបផតថលកាត់ទោសខ្មែរក្រហមកាលពីខែមុន----- ៧

**តារាង៤:** ទស្សនៈរបស់អ្នកទស្សនាអំពីមាតិការបស់វិបផតថលនេះ------------------------------------------ ៨

**តារាង៥:** កម្រិតចាប់អារម្មណ៍របស់អ្នកទស្សនាលើវិបផតថលនេះ------------------------------------------ ៨

**តារាង៦:** ភាពពេញលេញនៃព័ត៌មានសម្រាប់ការស្វែងរក ---------------------------------------------------- ៩

**តារាង៧:** ភាពពេញលេញនៃមាតិការវាងការប្រកាស និងសារព័ត៌មាន------------------------------------ ៩

**តារាង៨:** កម្រិតសំខាន់នៃព័ត៌មាននៅក្នុងវិបផតថលនេះ---------------------------------------------------- ១០

**តារាង៩:** យោបល់អំពីវិបផតថលនេះ ------------------------------------------------------------------------ ១១

**តារាង១០:** ចំណុចខ្លាំង និងចំណុចខ្សោយនៃវិបផតថលនេះ------------------------------------------------ ១២

**តារាង១១:** មាតិកានៅក្នុងវិបផតថលនេះដែលអ្នកអានស្វែងរក-------------------------------------------- ១៣

**តារាង១២:** បញ្ជីអត្ថបទនៅក្នុងវិបផតថលនេះដែលមានសារៈសំខាន់បំផុតដល់អ្នកអាន----------------- ១៤

# បញ្ជីរូបភាព


**រូបភាព១:** កម្រិតនៃការរចនាវិបផតថលនេះ------------------------------------------------------------------------ ៧

**រូបភាព២:** កម្រិតនៃមាតិការបស់វិបផតថលនេះ------------------------------------------------------------------ ៧

**រូបភាព៣:** ជំនឿរបស់អ្នកទស្សនាក្នុងការស្វែងរកព័ត៌មានដោយសំចៃពេលវេលា------------------------- ៨

**រូបភាព៤:** ភាពចាំបាច់នៃវិបផតថលនេះ-------------------------------------------------------------------------- ១០

**រូបភាព៥:** សារៈសំខាន់នៃវិបផតថលនេះ------------------------------------------------------------------------- ១១

**រូបភាព៦:** ប្រសិនបើអ្នកចង់ចូលមើលព័ត៌មានអំពីការកាត់ទោសខ្មែរក្រហមនៅក្នុងវិបនេះ ------------- ១៣

# របាយការណ៍ស្ទង់មតិ នៃវិបផតថលការកាត់ទោសមេដឹកនាំខ្មែរក្រហម

## ១_សារតា

គម្រោងវិបផតថលកាត់ទោសមេដឹកនាំខ្មែរក្រហម បានចាប់ផ្តើមតាំងពីឆ្នាំ២០០៥ ដើម្បីផ្តល់លទ្ធភាពដល់ប្រជាជនកម្ពុជា និងអ្នកនៅក្រៅប្រទេសមានលទ្ធភាពទទួលយកព័ត៌មានទាក់ទងនឹងនីតិវិធីនៅមុនពេល ក្នុងកំឡុងពេល និងក្រោយពេលកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលនឹងកើតឡើងនៅក្នុងប្រទេសកម្ពុជា។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលរួមគ្នាបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ បន្ទាប់ពីមានការចរចាអស់ពេលជាច្រើនឆ្នាំរវាងភាគីទាំងពីរទទួលខុសត្រូវលើការកាត់សេចក្តីនេះ។ វិបផតថលនេះ ជាដំបូងរចនាឡើងជាភាសាខ្មែរ ដោយអង្គការវេទិកាទូទៅនៃកម្ពុជា។ ស្ថិតក្រោមការគ្រប់គ្រងទាំងបច្ចេកទេស និងមាតិកាដោយអង្គការវេទិកាទូទៅនៃកម្ពុជា និងដោយមានការគាំទ្រពីវិទ្យាស្ថានសង្គមបើកទូលាយ គម្រោងវិបផតថលនេះនៅតែបន្តដំណើរការទៅមុខ រួមទាំងការបង្កើតផតថលបន្ថែមជាភាសាអង់គ្លេសមួយទៀត។ វិបផតថលនេះ បង្កើតឡើងក្នុងគោលបំណងផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ទាំងនៅកម្រិតជាតិ និងអន្តរជាតិ។ តាមរយៈវិបផតថលនេះ អង្គការវេទិកាទូទៅនៃកម្ពុជាមានបំណងធានាថា ទស្សនៈទាំងអស់ដែលពាក់ព័ន្ធនឹងប្រធានបទការកាត់ទោសមេដឹកនាំខ្មែរ ក្រហម ត្រូវបានផ្តល់ដល់ ប្រជាជន ទាំងក្នុង និងក្រៅប្រទេស នូវលទ្ធភាព ស្មើគ្នាក្នុង ការ ទទួល បាន នូវព័ត៌មាន។ អង្គការវេទិកាទូទៅនៃ កម្ពុជា ក៏បង្កើតនូវការពិភាក្សាតាមបែបស្ថាបនា និងជំរុញការ ប្រាស្រ័យទាក់ទងលើប្រធានបទនេះដែលជាការរួមចំណែកដល់ការកសាងសង្គមមួយមានសន្តិភាព និងប្រជាធិបតេយ្យ និងការលើកកម្ពស់យុត្តិធម៌។

អង្គការក៏សង្ឃឹមផងដែរថា តម្លាភាពក្នុងដំណើរការ ដែលបង្កើតឡើងដោយវិបផតថលនេះ ជួយរក្សានូវមូលដ្ឋាន សីលធម៌នៃការកាត់សេចក្តី ដែលធានាក្នុងការនាំមកនូវយុត្តិធម៌ជូនជនរងគ្រោះ។ វិបផតថលនេះដើរតួនាទីសំខាន់ក្នុងការពាំនាំព័ត៌មានពីរដ្ឋាភិបាល តុលាការ និងស្ថាប័នពាក់ព័ន្ធទៅឱ្យប្រជាជន ហើយពាំនាំផងដែរនូវអារម្មណ៍របស់ប្រជាជន ជនរងគ្រោះ សាក្សី និងការវិនិច្ឆ័យ គំនិត និងការសង្កេតរបស់ពួកគេទៅឱ្យរដ្ឋាភិបាល និងតុលាការ។ ព័ត៌មានបែបនេះជួយប្រជាជនក្នុងការធ្វើឱ្យជាសះស្បើយនូវការឈឺចាប់ផ្នែកផ្លូវចិត្តរបស់ពួកគេ។ ដោយមានផ្សាយព័ត៌មានពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ នីតិវិធីនៃការកាត់សេចក្តី សម្លេងរបស់សាក្សី។ល។ វិបផតថលនេះ ផ្តល់ជូនប្រជាជននូវរូបភាពទាំងមូលនៃបញ្ហាទាំងអស់នេះ។

វិបផតថលនេះមានព័ត៌មានទាក់ទងនឹងការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម និងព័ត៌មានអំពីសកម្មភាព របស់ ស្ថាប័ន ដែលធ្វើការក្នុងវិស័យដែលទាក់ទង។ អង្គការបានធ្វើកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធនឹង ការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ដើម្បីទទួលព័ត៌មានដែលគេដាក់បញ្ចូលទៅក្នុងវិបផតថល។

**វិបផតថលនេះ មានគោលបំណងដូចខាងក្រោម:**

១. ដើម្បីធានាថា រាល់ព័ត៌មានទាំងអស់ទាក់ទងនឹងការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ដែលប្រមូលពីស្ថាប័ននានាដែលធ្វើការពាក់ព័ន្ធនឹងបញ្ហានេះ និងពីសារព័ត៌មានមាននៅលើទំព័រវិបផតថល ហើយងាយស្រួលចូលទៅយកតាមរយៈវិបផតថលនេះ

២. ដើម្បីផ្តល់ជាឧបករណ៍សម្រាប់អ្នកទស្សនាវិបផតថល និងអ្នកដែលចាប់អារម្មណ៍ ដើម្បីអាចធ្វើការផ្លាស់ប្តូរនូវទស្សនៈយោបល់ជុំវិញដំណើរការកាត់សេចក្តី

៣. ដើម្បីជំរុញឱ្យមានការចែករំលែកនូវគំនិតរបស់ប្រជាជន តាមរយៈឧបករណ៍នេះ និងវិធី ដទៃទៀត។ បទពិសោធន៍ និងមេរៀនពីតុលាការអន្តរជាតិ ក៏ត្រូវជំរុញលើកទឹកចិត្តឱ្យចែករំលែកផ្តល់ដល់ប្រជាជនកម្ពុជានូវឱកាសរៀនសូត្រពីប្រទេសនានាលើបញ្ហាបែបនេះ។

ក្នុងរយៈពេលពីរឆ្នាំនៃការអនុវត្តរបស់ខ្លួន វិបផតថលនេះគឺជាវិបសាយដែលមានប្រជាប្រិយភាពយ៉ាងខ្លាំង តាមរយៈការស្វែងរកព័ត៌មានក្នុងម៉ាស៊ីន (search engine) តាមរយៈ Google, Yahoo។ល។ លើសពីនេះទៀត មានវិបសាយជាច្រើនបានភ្ជាប់ទៅវិបផតថលកាត់ទោសមេដឹកនាំខ្មែរក្រហម។ ទាំងប្រជាជនកម្ពុជា និងបរទេសកំពុងប្រើវិបផតថលនេះ ដើម្បីអាន និងស្វែងរកព័ត៌មានពីការកាត់ទោសមេដឹកនាំខ្មែរក្រហម និងដំណើរ ការកាត់ទោសនេះ ។ ដោយសារវិបផតថលមានសារៈសំខាន់ រួម ចំណែក ក្នុង ដំណើរ ការ កាត់ទោសមេដឹកនាំ ខ្មែរ ក្រហមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វាមានភាពចាំបាច់ ដែលវិបផតថល នេះត្រូវ ធ្វើ ឱ្យ ប្រសើរ ឡើងថែមទៀត និងផ្តល់នូវព័ត៌មានសំបូរបែប និងល្អៗដល់អ្នកអាន ដែល មាន ចំនួន កាន់ តែច្រើន ឡើង។ ដោយមានមហិច្ឆិតាក្នុងការដើរតួនាទីសំខាន់ជាបណ្តុំ និង ការរំលែកព័ត៌មាន អំពី ការ កាត់ទោសមេដឹកនាំ ខ្មែរក្រហម អង្គការវេទិកាទូទៅនៃកម្ពុជា បានធ្វើការស្ទាបស្ទង់មតិ លើវិបផតថល ដើម្បី ពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការបំពេញតួនាទីសំខាន់ក្នុងយុគសម័យបច្ចេកវិទ្យាព័ត៌មាន។

**គោលបំណងនៃការស្ទង់មតិ**

គោលបំណងនៃការស្ទង់មតិនេះ គឺដើម្បីផ្តល់ជាករណីសិក្សាមួយនៃវិបផតថលកាត់ទោសមេដឹកនាំខ្មែរក្រហម ដើម្បីអភិវឌ្ឍ និងធ្វើឱ្យប្រសើរឡើងនូវវិបផតថលនេះ។ ផ្នែកទីពីរ គឺរុករកនូវបញ្ហា និង យុទ្ធសាស្ត្រនានា ដើម្បីធ្វើឱ្យវិបផតថលកាន់តែមានភាពទាក់ទាញ និងប្រជាប្រិយ។ គោលបំណងនៃការស្ទង់មតិនេះគឺ:

- ដើម្បីដឹងពីកម្រិតនៃភាពសំខាន់នៃវិបផតថល ដែលមានបំណងផ្តល់នូវឱកាសដល់ សាធារណជននូវឱកាសស្មើគ្នាក្នុងការទទួលយកព័ត៌មាន

- ដើម្បីបង្ហាញអំពីប្រភេទព័ត៌មានដែលសាធារណជនចង់ឱ្យដាក់បញ្ចូលក្នុងវិបផតថល
- ដើម្បីកំណត់អំពីកម្រិតយល់ដឹងរបស់ប្រជាជន និងការគាំទ្ររបស់ពួកគេលើវិបផតថលនេះ ក្នុងកំឡុងពេលធ្វើការស្ទង់មតិទាក់ទងនឹងការស្វែងរកព័ត៌មានគុណភាពមាតិកាការរចនា។ល។
- ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្រនានា ដើម្បីធ្វើឱ្យវិបផតថលនេះមានភាពទាក់ទាញ និងមានប្រជាប្រិយ។

## វិធីសាស្ត្រស្ទង់មតិ

ទិន្នន័យដែលប្រើក្នុងការស្ទង់មតិនេះ ប្រមូលពីប្រភពទិន្នន័យបឋម។ ទិន្នន័យបឋម គឺជាទិន្នន័យដែលប្រមូលបានពីការសម្ភាសន៍ដោយប្រើវិធីសាស្ត្របែបបរិមាណ។ ដោយសារអ្នកឆ្លើយតបមានពេលវេលាតិចតួច ការឆ្លើយតបទៅនឹងសំណួររបស់អ្នកឆ្លើយតបទៅកាន់អ្នកសម្ភាសន៍ គឺជាវិធីសាស្ត្រដែលស័ក្តិសមបំផុតសម្រាប់ការស្ទាប់ស្ទង់មតិនេះ ដែលជាទូទៅអ្នកឆ្លើយតបចំណាយពេលវេលាតិចជាងវិធិសាស្ត្រដទៃ។ អ្នកឆ្លើយតបនៅទីក្រុងភ្នំពេញចំណាយពេលភាគច្រើនទៅលើការងាររបស់ពួកគេ។ ពួកគេមានពេលវេលាតិចតួចដើម្បីឆ្លើយតបមក កាន់ អ្នកសម្ភាសន៍។ ក្នុងលក្ខខណ្ឌនេះ ការស្ទង់មតិនេះធ្វើឡើងគឺអាស្រ័យទៅលើពេលវេលារបស់អ្នកឆ្លើយតបដែលនៅសល់ទំនេរពីការងារ។ ព័ត៌មានដែលបានពីបញ្ជីសំណួរ និងការសម្ភាសន៍ទុកជាសម្ងាត់។ អ្នកសម្ភាសន៍ណែនាំអំពីគោលបំណងនៃការស្ទង់មតិនេះដល់អ្នកឆ្លើយតប។ អ្នកឆ្លើយតប ឬអ្នកផ្តល់ព័ត៌មានមានសេរីភាពក្នុងការឆ្លើយសំណួរ។ ការស្ទង់មតិនេះប្រើអស់រយៈពេលពីរខែកន្លះ ចាប់ពីថ្ងៃទី១៥ ខែមករា ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧។ ការចុះប្រមូលចម្លើយដល់ទីកន្លែងធ្វើឡើងនៅចុងសប្តាហ៍នៃខែកុម្ភៈ និងសប្តាហ៍ទី១ នៃខែមីនា ឆ្នាំ២០០៧។ ហើយរបាយការណ៍ចុងក្រោយបានធ្វើហើយនៅចុងខែមីនា។ ការវិភាគទិន្នន័យប្រើ SPSS 12.0។ ព័ត៌មានដែលដកស្រង់ពីសំណួរត្រូវបានវិភាគ និងព័ត៌មានដែលទទួលបានពីអ្នកផ្តល់ចម្លើយសំខាន់ៗត្រូវបានដកស្រង់សម្តី។ភ្នំពេញគឺជាតំបន់សិក្សា ព្រោះជាទីកន្លែងដែលសេវាកម្មអ៊ិនធឺណេតមានច្រើនបើប្រៀបធៀបនឹងកន្លែងដទៃ។

## ចំនួន និងសំណៅ

ការស្ទង់មតិនេះ ធ្វើឡើងដោយសម្ភាសន៍មនុស្សចំនួន១២៦នាក់ ក្នុងនោះ ៣០ នាក់ធ្លាប់ចូលមើលវិបផតថលកាត់ទោសមេដឹកនាំខ្មែរក្រហម និង៩៦នាក់ទៀតមិនធ្លាប់ចូលមើលទេ។ ក្នុងចំណោមអ្នកឆ្លើយតបចំនួន៣០នាក់ មាន២៥នាក់ប្រុស និង៥នាក់ស្រ្តី ហើយពួកគេភាគច្រើនធ្វើការទាក់ទងនឹងគម្រោងកាត់ទោសមេដឹកនាំខ្មែរក្រហម។ ភាគច្រើននៃអ្នកឆ្លើយចំនួន ៩៦ នាក់ គឺជានិស្សិតដែលជាក្មេងជំនាន់ក្រោយរបស់ប្រជាជនកម្ពុជាដែលធ្លាប់រងគ្រោះពីរបបខ្មែរក្រហមក្នុងកំឡុងខែមេសា១៩៧៥ ដល់ ខែមករា ១៩៧៩។ ពួកគេឥឡូវនេះធំដឹងក្តីនៅក្នុងសង្គមកម្ពុជាទំនើបដែលកំពុងសម្របខ្លួនទៅក្នុងសាកលភាវូបនីយកម្ម និងបច្ចេកវិទ្យាព័ត៌មាន។ ក្នុងចំណោមយុវជនទាំងនេះ៦០នាក់ ជាបុរស និង៣៦នាក់ជាស្រ្តី។

ការកំណត់យកអ្នកឆ្លើយតបគោលដៅខុសគ្នាដូចនេះ គឺដើម្បីធ្វើការប្រៀបធៀបរវាងអ្នកធ្លាប់ចូលមើលវិបផតថល និងអ្នកមិនធ្លាប់ចូលមើលវិបផតថល និងជាយុវជន ដែលយល់ពីអ៊ិនធឺណេតជាងអ្នកជំនាន់មុននៃជនរងគ្រោះដោយសាររបបខ្មែរក្រហម។ ក្នុងកម្រិតណា វិសាលភាពត្រឹមណា យុវជនដែលមានអាយុពី១៩ឆ្នាំដល់២៥ឆ្នាំ ដែលយ៉ាងហោចណាស់៥០% ក្នុងចំណោមពួកគេយល់ពីអ៊ិនធឺណេត វិបសាយ ហើយស្ថិតក្នុងវ័យសិក្សាស្រាវជ្រាវបានចូលមើលគេហទំព័រ ដើម្បីស្វែងអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហម។

**បញ្ហាប្រឈម**

មានឧបសគ្គមួយចំនួន បានកើតឡើងនៅក្នុងការស្ទាបស្ទង់មតិនេះ។ លទ្ធភាពទទួលព័ត៌មានមានកម្រិតពីអ្នកឆ្លើយតបដែលធ្លាប់ចូលមើលវិបផតថល ពេលវេលាមានកម្រិតរបស់អ្នកឆ្លើយតប និងពេលវេលាខ្លីសម្រាប់ការស្ទង់មតិនេះបានតម្រូវឱ្យការស្ទង់មតិនេះសម្រេចចិត្តកំណត់យកអ្នកឆ្លើយតបចំនួន៣០នាក់។

**ផែនការបញ្ជីសំណួរ**

ប្រភេទសំណួរដែលប្រើនៅក្នុងដំណើរនេះគឺភាគច្រើនជាសំណួរបិទ ប៉ុន្តែមានអមជាមួយសំណួរបើកដែលទាក់ទងនឹងគំនិតយោបល់របស់ពួកគេលើវិបផតថលនេះ។ បញ្ជីសំណួរចែកចេញពីរផ្នែក។ ផ្នែកទី១ គឺជាសំណួរសម្រាប់អ្នកឆ្លើយតប ដែលធ្លាប់ចូលមើលវិបផតថលកាត់ទោសមេដឹកនាំខ្មែរក្រហម និងផ្នែកទី២គឺសម្រាប់អ្នកឆ្លើយតបដែលពុំធ្លាប់ចូលមើលវិបផតថល។ បញ្ជីសំណួរចែកចេញជាបីសាច់រឿង គឺព័ត៌មានផ្ទាល់ខ្លួនទាក់ទងនឹងអប់រំការងារ។ល។ ចំណេះដឹងអំពីតុលាការខ្មែរក្រហម និងគំនិតអំពីវិបផតថល។

## ២_របកគំហើញពីការស្ទាបស្ទង់មតិ

*ជាមួយអ្នកធ្លាប់ចូលមើលវិបផតថល

ប្រភពប្រជាប្រិយភាពរបស់វិបផតថលកាត់ទោសមេដឹកនាំខ្មែរក្រហម

ក្នុងចំណោមអ្នកឆ្លើយតបដែលធ្លាប់ចូលមើលវិបផតថល៧០% យល់ព្រមថា ពួកគេស្គាល់វិបផតថលនេះតាមរយៈការបោះពុម្ពផ្សាយដែលសំដៅលើសម្ភារៈផ្សព្វផ្សាយ[1] របស់អង្គការវេទិកាទូទៅនៃកម្ពុជា ដែលបានផលិត និងចែកផ្សាយទៅសាធារណៈជននៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តគម្រោងក្នុងឆ្នាំ២០០៥។ ទោះបីយ៉ាងណាក៏ដោយ មានប្រហែល១៥% បានស្គាល់វិបផតថលតាមរយៈម៉ាស៊ីនស្វែងរកព័ត៌មាន(search engine) និងមិត្តភក្តិ។ តួលេខនេះបង្ហាញថា ការផ្សព្វផ្សាយអំពីវិបផតថលតាមរយៈការបោះពុម្ពផ្សាយមានប្រសិទ្ធភាពខ្ពស់ជាង ខណៈដែលការស្គាល់តាមរយៈម៉ាស៊ីនស្វែងរក និងមិត្តភក្តិមានប្រសិទ្ធភាពតិចជាង។ វាហាក់បីដូចជាមានន័យថា គេមិនអាចងាយស្គាល់វិបផតថលនេះតាមរយៈម៉ាស៊ីនស្វែងរកទេ ហើយការផ្សាយផ្ទាល់ពីមាត់មួយទៅមាត់មួយ គួរតែធ្វើឡើងក្នុងចំណោមបុគ្គលិករបស់អង្គការវេទិកាទូទៅនៃកម្ពុជាដោយប្រាប់អ្នកដទៃអំពីគម្រោង និងវិបផតថលនេះ។ ប្រការនេះអាចធ្វើបានតាមរយៈសិក្ខាសាលា ឬកិច្ចប្រជុំនានាដែលពិភាក្សាអំពី

[1] Promotion materials are leaflets, brochures, and stickers.

ប្រធានបទពាក់ព័ន្ធនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយសហការ និងភាពជាដៃគូរ ជាមួយ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល។

**តារាងទី១: ប្រភពនៃការផ្សព្វផ្សាយអំពីវិបផតថលការកាត់ទោសមេដឹកនាំខ្មែរក្រហម**

| ប្រភពនៃការផ្សព្វផ្សាយអំពីវិបផតថលការកាត់ទោសមេដឹកនាំខ្មែរក្រហម | ចំនួន | ភាគរយ |
|---|---|---|
| ការបោះពុម្ពផ្សាយ | ២១ | ៧០,០ |
| ស្វែងរកតាមអ៊ិនធឺណេត | ៥ | ១៦,៧ |
| មិត្តភក្តិ | ៣ | ១០,០ |
| ផ្សេងៗ | ១ | ៣, ៣ |
| សរុប | ៣០ | ១០០,០ |

**មធ្យោបាយចូលទៅយកព័ត៌មាន**

ពុំមានការសង្ស័យដែលថា ១០០% នៃអ្នកឆ្លើយតប ស្វែងរកព័ត៌មានអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយចូលមើលវិបផតថល www.krtrial.info ពីព្រោះ ពួកគេគឺជាអ្នកឆ្លើយតប ដែលធ្លាប់ចូលមើលវិបផតថលកាត់ទោសមេដឹកនាំខ្មែរក្រហម។ វាពុំមានន័យថា វិបផតថលនេះមានប្រជាប្រិយភាពបំផុត។ ទោះជា យ៉ាងណាក៏ដោយ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា គេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏មានប្រជាប្រិយ ភាព ដោយសារក្នុងចំណោមអ្នកឆ្លើយតប៦០% ធ្លាប់ចូលមើលព័ត៌មានអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហមពីគេហទំព័រនេះ។

ក្រៅពីគេហទំព័រនេះ៧៣, ៣% នៃអ្នកឆ្លើយតបបានរៀនអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមរយៈវិទ្យុ ៨៣, ៣% តាមរយៈកាសែត ៥៦,៧% តាមរយៈការបោះពុម្ពផ្សាយ ៣៣, ៣% តាមរយៈទូរទស្សន៍ និង ២៣, ៣% តាមរយៈ មិត្តភក្តិ។ តួលេខនេះបង្ហាញថា គេមិនរៀនចេះដឹងអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហមច្រើនទេ តាមរយៈទូរទស្សន៍ និងមិត្តភក្តិ ហើយប្រការនេះគឺប្រហែលមកពីទូរទស្សន៍មិនសូវមាន ឬគ្មានកម្មវិធីទាក់ទង នឹង ការកាត់ទោសមេដឹកនាំខ្មែរក្រហម។ ផ្ទុយទៅវិញ គេរៀនចេះដឹងអំពីបញ្ហានេះបានច្រើន តាមរយៈវិទ្យុ។

ប្រសិនបើប្រៀបធៀបនឹងមធ្យោបាយដែលគេអាចរៀនអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហម តាមរយៈគេហទំព័រ និងមិនតាមគេហទំព័រតួលេខបង្ហាញថា សូម្បីតែក្នុងចំណោមអ្នកដែលធ្លាប់ចូលមើលវិបផតថលការកាត់ទោស មេដឹកនាំ ខ្មែរក្រហម មានទំនោររៀនអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមរយៈវិទ្យុ និង កាសែតជាជាងគេហទំព័រ។ អ្នកដែលសិក្សាអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហម មិនតាមរយៈវិបផតថលការកាត់

ទោសមេដឹកនាំខ្មែរក្រហមមានតិចជាង៦១% ហើយអ្នករៀនអំពីបញ្ហានេះតាមមធ្យោបាយផ្សេងក្រៅពីគេហទំព័រ (វិទ្យុ និងកាសែត) មានច្រើនជាង៧០%។ វាមានន័យថា ការកើនឡើងនូវការផ្សាយព័ត៌មានអំពីការកាត់ទោសនេះ តាមរយៈវិទ្យុ និងកាសែត គួរបន្ថែមទៀត បន្ថែមលើគេហទំព័រ ដែលគេអាចរៀនអំពី ការ កាត់ទោសមេដឹកនាំខ្មែរក្រហមនៅពេលណាក៏បានទីកន្លែងណាក៏បាន។

**តារាងទី២: អ្នកឆ្លើយតបដែលធ្លាប់ចូលមើលព័ត៌មានអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហម**

| មធ្យោបាយចូលមើលព័ត៌មាន | អ្នកឆ្លើយតប/ភាគរយ | | |
|---|---|---|---|
| | បាន / ចាំ | ទេ | សរុប |
| www.krtrial.info | 100.0% | 0.0% | 100.0% |
| www.genocidewatch.org | 13.3% | 86.7% | 100.0% |
| www.cgp.org | 6.7% | 93.3% | 100.0% |
| www.dccam.org | 60.0% | 40.0% | 100.0% |
| www.un.org/law/khmerrougetrials | 16.7% | 83.3% | 100.0% |
| www.cambodia.gov.kh/krt | 36.7% | 63.3% | 100.0% |
| www.eccc.gov.kh | 40.0% | 60.0% | 100.0% |
| វិទ្យុ | 73.3% | 26.7% | 100.0% |
| កាសែត | 83.3% | 16.7% | 100.0% |
| ទូរទស្សន៍ | 33.3% | 66.7% | 100.0% |
| សាច់ញាតិ/មិត្តភក្តិ | 31.3% | 68.8% | 100.0% |
| ឯកសារបោះពុម្ព | 56.7% | 43.3% | 100.0% |
| ផ្សេងទៀត | 3.3% | 96.7% | 100.0% |

**ចំនួនដងនៃការស្វែងរកព័ត៌មានតាមរយៈវិបផតថលការកាត់ទោសមេដឹកនាំខ្មែរក្រហម**

កាលពីខែមុន អ្នកឆ្លើយតបជាច្រើនទំនងចូលចិត្តស្វែងរកវិបផតថលម្តងក្នុងមួយសប្តាហ៍ (៣៣,៣%) និងបន្តបន្ទាប់ពីរដង ឬបីដង ក្នុងមួយសប្តាហ៍ ១៦,៧% និង ៦ ថ្ងៃ ក្នុង១ សប្តាហ៍ ១៣,៣% និង រៀងរាល់ថ្ងៃប្រហែល១០%។ វាមិនមែនជាចំនួនខ្ពស់ទេ (៣៣,៣%) ហើយប្រការនេះដោយសារការពិតដែលថា ការស្វែង រកព័ត៌មានតាមរយៈគេហទំព័រ គឺមិនមែនជាទម្លាប់ក្នុងចំណោមប្រជាជនកម្ពុជាភាគច្រើន ក្នុង ខណៈពេលដែលសេវាកម្មអ៊ិនធឺណេតមានតម្លៃថ្លៃ បើប្រៀបធៀបនឹងប្រទេសអាស៊ានអ្នកទាំងឡាយដែលធ្វើការពេញម៉ោងពុំមានពេលវេលាច្រើន ដើម្បីស្វែងរកព័ត៌មានអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមរយៈគេហទំព័រ ហើយអ៊ិនធឺណេត ជាធម្មតាមាននៅកន្លែងធ្វើការ ហើយមិនមានទេនៅឯផ្ទះ។ ពុំមានតួលេខជាក់លាក់ អំពី ចំនួនកំព្យូទ័រដែលគេប្រើនៅផ្ទះ ក៏ប៉ុន្តែគេអាចនិយាយបានថា សូម្បីក្នុងចំណោមបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល

ទាំងអស់ ក៏មិនមានកំព្យូទ័រប្រើនៅផ្ទះដែរ។ កង្វះការប្រើប្រាស់កំព្យូទ័រនាំទៅដល់កង្វះនៃការប្រើប្រាស់ អ៊ិនធឺណេតនៅផ្ទះ ពីព្រោះអ៊ិនធឺណេតត្រូវការកំព្យូទ័រ។

**តារាងទី៣:ចំនួនដងនៃការស្វែងរកព័ត៌មានតាមរយៈគេហទំព័រកាលពីខែមុន**

| **ចំនួនដង** | **ចំនួនអ្នកឆ្លើយតប** | **ភាគរយ** |
|---|---|---|
| មួយដងក្នុងមួយសប្តាហ៍ | 10 | 33.3 |
| ពីរដងក្នុងមួយសប្តាហ៍ | 5 | 16.7 |
| បីដងក្នុងមួយសប្តាហ៍ | 5 | 16.7 |
| បួនដងក្នុងមួយសប្តាហ៍ | 1 | 3.3 |
| ប្រាំដងក្នុងមួយសប្តាហ៍ | 2 | 6.7 |
| ប្រាំមួយដងក្នុងមួយសប្តាហ៍ | 4 | 13.3 |
| ជារៀងរាល់ថ្ងៃ | 3 | 10.0 |
| សរុប | **30** | **100.0** |

## ការរចនា និងមាតិកា

៩៣,៣% នៃអ្នកឆ្លើយតបឆ្លើយថា វិបផតថលនេះមានការរចនាល្អ ហើយ ៨៦,៧% បាននិយាយថា វិបផតថលនេះ មានមាតិកាល្អ (ដូចជាអង្គជំនុំជម្រះវិមសាមញ្ញ មតិជនរងគ្រោះ ប្រវត្តិខ្មែរក្រហម ឯកសារបណ្ណាល័យ។ល។) ចំណុចនេះបង្ហាញអំពីកម្រិតខ្ពស់នៃការពេញចិត្តរបស់អ្នកចូលមើលវិបផតថល។ ដោយសារមានមាតិកា និងការរចនាល្អ អ្នកចូលមើល វិបផតថលនឹង មិនចំណាយ ពេលវេលា ច្រើន ដើម្បី ស្វែងរកព័ត៌មាននៅក្នុងវិបផតថលឡើយ។ អ្នកឆ្លើយតប៧៦,៧% ជឿថា ការស្វែងរកព័ត៌មានតាមរយៈវិបផតថលសន្សំពេលវេលាច្រើន។

**រូបភាព ១** : កម្រិតនៃការរចនាវិបផតថល




**រូបភាព ២** :កម្រិតនៃមាតិកាវិបផតថល



**រូបភាព ៣ :ជំនឿរបស់អ្នកទស្សនាក្នុងការស្វែងរកព័ត៌មានដោយអាចសន្សំពេលវេលាបាន**




## ការអានតាមរយៈវិបផតថលការកាត់ទោសមេដឹកនាំខ្មែរក្រហម

ជាង៧០% បានចាប់អារម្មណ៍ក្នុងការអានព័ត៌មានតាមរយៈវិបផតថល។ ទោះយ៉ាងណាក៏ដោយ តិចជាង ៥០%គិតថា ព័ត៌មាននៅលើវិបផតថលមិនមានច្រើនពេលលេញទេ ហើយប្រហែល៤៥%គិតថា មានព័ត៌មាន តិចតួច។ ដោយហេតុនេះ វិបផតថលពុំបានបំពេញនូវសេចក្តីត្រូវការទាំងស្រុងរបស់អ្នកចូលមើលព័ត៌មានទេ។ ៦០% នៃចំនួនអ្នកឆ្លើយតប ៣០ នាក់ ឆ្លើយថា ការស្វែងរកព័ត៌មានពុំឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេទេ ពីព្រោះវាពុំគ្រប់គ្រាន់។ តាមរយៈតួលេខនេះ វិបផតថលនេះគួរផ្តល់ព័ត៌មានដោយការជ្រើសរើសយ៉ាងប្រយ័ត្ន ប្រយែងច្រើនថែមទៀត ដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នកចូលមើលព័ត៌មាន។

**តារាងទី ៤ : ការយល់ឃើញរបស់អ្នកចូលមើលព័ត៌មានអំពីបរិមាណមាតិកាក្នុងវិបផតថល**

| បរិមាណ | ចំនួន | ភាគរយ |
|---|---|---|
| តិចតួច | 13 | 43.3 |
| ច្រើនពេញ | 14 | 46.7 |
| មិនដឹង | 2 | 6.7 |
| ផ្សេងៗ | 1 | 3.3 |
| សរុប | **30** | **100.0** |

**តារាងទី ៥ : កម្រិតចាប់អារម្មណ៍របស់អ្នកចូលមើលព័ត៌មានក្នុងវិបផតថល**

| កម្រិតចាប់អារម្ម | ចំនួន | ភាគរយ |
|---|---|---|
| មិនចាប់អារម្មណ៍ | 4 | 13.3 |
| ចាប់អារម្មណ៍ | 22 | 73.3 |
| មិនដឹង | 3 | 10.0 |
| ផ្សេងៗ | 1 | 3.3 |
| សរុប | **30** | **100.0** |

### តារាងទី ៦ : ភាពគ្រប់គ្រាន់នៃព័ត៌មានសម្រាប់ស្វែងរក

| ភាពគ្រប់គ្រាន់ | ចំនួន | ភាគរយ |
|---|---|---|
| មិនគ្រប់គ្រាន់ | 18 | 60.0 |
| គ្រប់គ្រាន់ | 10 | 33.3 |
| មិនដឹង | 2 | 6.7 |
| **សរុប** | **30** | **100.0** |

## ប្រៀបធៀបភាពគ្រប់គ្រាន់នៃសេចក្ដីជូនដំណឹងនិងព័ត៌មានប្រចាំថ្ងៃ

តិចជាង៤១% យល់ថា សេចក្ដីជូនដំណឹង និងព័ត៌មានប្រចាំថ្ងៃមានភាពគ្រប់គ្រាន់ ខណៈពេលដែលច្រើនជាង៥០% យល់ស្របហើយអះអាងថា មិនគ្រប់គ្រាន់។ ដោយពុំគិតដល់ពីកម្រិតនៃភាពសំខាន់លើមាតិកាទាំងពីរប្រភេទនេះ សេចក្ដីជូនដំណឹងនិងព័ត៌មានប្រចាំថ្ងៃត្រូវបន្ថែមទៀត ហើយដាក់បញ្ចូលក្នុងវិបផតថលឱ្យទាន់ពេលវេលា។ ការបង្កើនព័ត៌មានគឺចាំបាច់។

### តារាងទី ៧ : ភាពគ្រប់គ្រាន់នៃសេចក្ដីជូនដំណឹងនិងព័ត៌មានប្រចាំថ្ងៃ

| ប្រភេទព័ត៌មាន | មិនគ្រប់គ្រាន់ | | គ្រប់គ្រាន់ | | មិនដឹង | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| សេចក្ដីជូនដំណឹង | 16 | 53.3 | 6 | 20.0 | 8 | 26.7 |
| ព័ត៌មានប្រចាំថ្ងៃ | 15 | 50.0 | 12 | 40.0 | 3 | 10.0 |

## សារៈសំខាន់របស់វិបផតថល

នៅពេលដែលសួរអំពីសារៈសំខាន់នៃប្រភេទមាតិកានៃវិបផតថលរបស់ខ្មែរក្រហម អ្នកឆ្លើយតបចំនួន ៩៣,៣% បានដាក់ពិន្ទុថា ជាអង្គជំនុំជម្រះវិសាមញ្ញ និងជាប្រវត្តិខ្មែរក្រហមខណៈ ៩០% ដាក់ថា ជាឯកសារផ្លូវច្បាប់ ៨០% ដាក់ថា ជាយោបល់របស់ជនរងគ្រោះ ៧៦,៧% ដាក់ថា ជាស្ថាប័ន និងបណ្ណាល័យសម្រាប់ឯកសារពាក់ព័ន្ធ ៧០% ដាក់ថា ជាឯកសារសោតទស្សន៍ ៦០% ដាក់ថា ដើម្បីរកការគាំទ្រផ្នែកហិរញ្ញវត្ថុ និង ៥០% ដាក់ថា ជាកំណាព្យចម្រៀង និងជាអក្សរសិល្ប៍។ ទោះបីជាតួលេខទាំងនេះបង្ហាញថា ច្រើនជាង៥០% បានដាក់ពិន្ទុទៅលើសារៈសំខាន់លើព័ត៌មានទាំងអស់ ប៉ុន្តែព័ត៌មានគួរឱ្យកត់សំគាល់ គឺយើងគួរតែផ្តោតទៅលើអង្គជំនុំ ជម្រះវិសាមញ្ញ និង ប្រវត្តិខ្មែរក្រហម។ វាបញ្ជាក់អំពីតថភាពដែលប្រជាជនភាគច្រើនជាជនរងគ្រោះ និង ជាគ្រួសារជនរងគ្រោះនៅ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយប៉ងចង់ដឹងថា តើខ្មែរ ក្រហមពិត ប្រាកដ

ជានរណា ហើយតើអង្គជំនុំជម្រះវិសាមញ្ញ នឹងនាំយុត្តិធម៌ជូនជនរងគ្រោះបានឬទេ។ ដំណាក់កាលបន្ទាប់នៃគម្រោងវិបផតថលខ្មែរក្រហមនេះ ហើយសាលាក្តីនឹងបន្តកាត់ទោសមេដឹកនាំខ្មែរក្រហម ដូច្នេះវាមាន សារៈ_សំខាន់ ខ្លាំង ណាស់ដែលវិផលថលនឹងផ្តល់ព័ត៌មាន ច្រើនឥតគណនាអំពីអង្គជំនុំ ជម្រះវិសាមញ្ញ និង ប្រវត្តិ ខ្មែរក្រហម។

## តារាងទី ៨ : កម្រិតសំខាន់នៃព័ត៌មាននៅក្នុងវិបផតថល

| ប្រភេទព័ត៌មាន | អ្នកឆ្លើយតប / ភាគរយ | | | |
|---|---|---|---|---|
| | មិនសំខាន់ | សំខាន់ | មិនដឹង | សរុប |
| អង្គជំនុំជម្រះវិសាមញ្ញ | 3.3% | 93.3% | 3.3% | 100.0% |
| ស្ថាប័នពាក់ព័ន្ធ | 10.0% | 76.7% | 13.3% | 100.0% |
| ការគាំទ្រហិរញ្ញវត្ថុ | 16.7% | 60.0% | 23.3% | 100.0% |
| ឯកសារច្បាប់ | 3.3% | 90.0% | 6.7% | 100.0% |
| ឯកសារបណ្ណាល័យ | 3.3% | 76.7% | 20.0% | 100.0% |
| ប្រវត្តិខ្មែរក្រហម | 0.0% | 93.3% | 6.7% | 100.0% |
| យោបល់ជនរងគ្រោះ | 607% | 80.0% | 13.3% | 100.0% |
| កំណាព្យចម្រៀងអក្សរសិល្ប៍ | 20.0% | 50.0% | 30.0% | 100.0% |
| ឯកសារសោតទស្សន៍ | 3.3% | 70.0% | 26.7% | 100.0% |

### ភាពចាំបាច់និងសារសំខាន់នៃវិបផតថល

វាគួរឱ្យចាប់អារម្មណ៍ដែលអ្នកឆ្លើយតបជាច្រើនរហូតដល់៧៣,៣% បានចាប់អារម្មណ៍អានឯកសារ។ ៩៣,៣% នៃចំនួនអ្នកឆ្លើយតបសរុបបានឆ្លើយថា វិបផតថលនេះ គឺមានការចាំបាច់សម្រាប់អ្នកអាន ដើម្បីទទួលបានព័ត៌មានអំពីការកាត់ទោសខ្មែរក្រហម។

**រូបភាព ៤** : ភាពចាំបាច់នៃវិបផតថល



អ្នកឆ្លើយតបសរុប៩៣,៣% យល់ស្របថា វិបផតថលគឺមានសារៈសំខាន់សម្រាប់ពួកគេ។ វាមានន័យថា វិបនេះ មានសារៈសំខាន់ដោយខ្លួនឯង ដោយមិនមែនអាស្រ័យតែលើព័ត៌មានលើវិបនោះទេ។ អ្នកឆ្លើយតបមួយចំនួន ក្នុងចំណោមអ្នកឆ្លើយតបសរុប បានយល់ស្របថា វិបនេះបានផ្តល់ព័ត៌មានសំខាន់ៗដល់អ្នកអាន។ អ្នកឆ្លើយតប៩៦,៧% យល់ស្របថា វិបនេះគួរតែបន្តដំណើរការទៅមុខទៀត។

**រូបភាព ៥** : សារសំខាន់នៃវិបផតថល




លើសពីនេះទៅទៀតក្រុមអ្នកឆ្លើយតបចង់ឱ្យវិសាយនេះផ្តល់សេវាកម្មផ្សេងបន្ថែមទៀតទៅដល់ប្រជាជនសាមញ្ញដែលមិនបានធ្វើការនៅក្នុងគម្រោងកាត់ទោសខ្មែរក្រហម និងប្រជាជនដែលរស់នៅទីកន្លែងផ្សេងទៀតក្រៅពីទីក្រុងភ្នំពេញ។ អ្នកឆ្លើយតបសរុប៧៦,៧% បាននិយាយថា វិបផតថលនេះគួរត្រូវបានផ្សព្វផ្សាយឱ្យដល់គ្រប់ទិសទី ខណៈដែល២០% ផ្សេងទៀតប៉ុណ្ណោះដែលបានរាយការណ៍ថា វិបផតថលគួរត្រូវបានផ្សព្វផ្សាយនៅក្នុងទីក្រុងភ្នំពេញហើយអ្នកឆ្លើយតបទាំងអស់បានលើកថា វិបផតថលនេះគួរតែមានបន្ថែមព័ត៌មានផ្សេងទៀត។

**តារាងទី ៩ : យោបល់អំពីវិបផតថល**

| យោបល់ | អ្នកឆ្លើយតប / ភាគរយ | | | |
|---|---|---|---|---|
| | ត្រូវ | ខុស | មិនដឹង | សរុប |
| វិបផតថលផ្តល់ព័ត៌មានសំខាន់ | 100.0% | 0.0% | 0.0% | 100.0% |
| វិបផតថលគួរតែបន្ត | 96.7% | 0.0% | 3.3% | 100.0% |
| ផលលំបាកស្វែងរកព័ត៌មាននៅក្នុងវិបផតថលនេះ | 10.0% | 83.3% | 6.7% | 100.0% |
| វិផតថលគួរបានផ្សព្វផ្សាយគ្រប់ទីកន្លែង | 76.7% | 13.3% | 10.0% | 100.0% |
| វិបផតថលគួរផ្សព្វផ្សាយតែក្នុងក្រុងភ្នំពេញ | 20.0% | 73.3% | 6.7% | 100.0% |
| វិបផតថលគួរបន្ថែមព័ត៌មានផ្សេងទៀត | 100.0% | 0.0% | 0.0% | 100.0% |

ភាពខ្លាំង និងភាពខ្សោយរបស់វិបផតថល

**តារាងទី ១០ : ចំណុចខ្លាំង និងចំណុចខ្សោយរបស់វិបផតថល**

| ចំណុច | អ្នកឆ្លើយតប / ភាគរយ | | | | |
|---|---|---|---|---|---|
| | មិនល្អ | មធ្យម | ល្អ | មិនដឹង | សរុប |
| មាតិកា | 0.0% | 63.3% | 30.0% | 6.7% | 100.0% |
| ការរចនាវិប | 3.3% | 60.0% | 33.3% | 3.3% | 100.0% |
| ទាន់ពេលវេលា | 23.3% | 56.7% | 10.0% | 10.0% | 100.0% |

ដូចដែលបានពិពណ៌នាខាងលើ ៦០%នៃអ្នកឆ្លើយតបបានលើកថា ព័ត៌មាន ដែលដាក់បង្ហាញ ដូច ជាអង្គជំនុំ ជម្រះវិសាមញ្ញ យោបល់ជនរងគ្រោះ ប្រវត្តិខ្មែរក្រហម ឯកសារបណ្ណាល័យ ។ល។ មិនបាន បំពេញតម្រូវការពួកគេនោះទេ។ ទាក់ទិនបញ្ហានេះ អ្នកឆ្លើយតប៦៣,៣% បានយល់ស្របថា មាតិការបស់វិបនេះគឺមានកម្រិតមធ្យម៣០% ថា មានកម្រិតល្អ៦០% ថា ការរចនាវិបនេះមានកម្រិតមធ្យម និង៣៣,៣% ថា មានកម្រិត ល្អ (សូមមើលតារាង៦) ។ កម្រិតមធ្យមនៅក្នុងករណីនេះ គឺទំនងជាអាចទទួលយកបាន ប៉ុន្តែ មិនមានន័យថា ល្អនោះទេដែលវាប្រហាក់ប្រហែលគ្នានឹងកម្រិតល្អ។ លទ្ធផលនៃកម្រិតមធ្យមអាចកើតមកពីការរចនា សំណួរ ជាជាងគំនិតរបស់អ្នកឆ្លើយតប ពីព្រោះយើងផ្តល់ឱ្យពួកគេត្រឹមតែកម្រិតល្អ មធ្យម និង មិនល្អ ដែល ដូច្នេះ អ្នកឆ្លើយតបទំនងជាជ្រើស យកចំណុចកណ្តាលដែលជាកម្រិតមធ្យម ជាជាងចំណុចល្អ និងមិនល្អ។ជាជាងនេះ ទៅទៀត យើងបានសួរសំណួរដូចគ្នាខាងលើនេះ ហើយអ្នកឆ្លើយតបភាគច្រើនលើកថា បញ្ជីមាតិកាគឺមានកម្រិតល្អ ដែលចំណុចនេះកម្រិតមធ្យមនៅក្នុងករណីនេះ គឺទំនងជាកម្រិតល្អ។

ចំណុចគួរឱ្យចាប់អារម្មណ៍ទាក់ទងទៅនឹងភាពទាន់ពេលវេលា អ្នកឆ្លើយតប ៥៦,៧% បានលើកថា វាមានកម្រិតមធ្យម ២៣,៣% លើកថា វាមានកម្រិតមិនល្អ ហើយ១០%ទៀតថា មានកម្រិតល្អ។ ក្នុងករណីនេះ អ្នកឆ្លើយតបបានរាយការណ៍ថា ពួកគេមិនសូវគាំទ្រថា ព័ត៌មានដាក់បង្ហាញនៅក្នុងវិបមានលក្ខណៈទាន់ពេល វេលា។ ជាការពិត វិបផតថល អាចមិនឆ្លើយតបទៅនឹងតម្រូវការអ្នកអាន ពីព្រោះវិបផតថល គឺជា ការប្រមូល អត្ថបទ និងព័ត៌មាន ដែលជ្រើសចេញពី ECCC អង្គការមិនមែនរដ្ឋាភិបាល និង សារព័ត៌មាន ទូទៅផ្សេងទៀត។

**អ្នកមើលវិបផតថលដែលមិនទាក់ទងការកាត់ទោសខ្មែរក្រហម**

សម្រាប់អ្នកឆ្លើយតបដែលមិនស្វែងរកវិបផតថល គឺ ៨០,២% ក្នុងចំណោមពួកគេនឹងស្វែងរកវិបប្រសិនបើពួកគេដឹងអំពីវា។

រូបភាព ៤ ៖ ប្រសិនបើអ្នកចង់ចូលរកព័ត៌មានអំពីការកាត់ទោសខ្មែរក្រហមនៅក្នុងវិបសាយ




រូបភាពទី៤ បង្ហាញថា អ្នកឆ្លើយតប ដែលមិនស្វែងរកវិបផតថល តែងនឹងស្រមៃថា ប្រសិនបើ ពួក គេ ស្វែងរក ព័ត៌មានតាមរយៈវិបផតថលកាត់ទោសខ្មែរក្រហម ពួកគេ ៦០,៤% នឹងពិនិត្យមើលអង្គជំនុំជម្រះវិសាមញ្ញ ៥៨,៣% នឹង ពិនិត្យមើលស្ថាប័នពាក់ព័ន្ធ ៣៣,៣% នឹងស្វែងរកការគាំទ្រហិរញ្ញវត្ថុ ៥២,១% នឹង ពិនិត្យ មើលឯកសារច្បាប់ ២៩,២% ពិនិត្យមើលឯកសារបណ្ណាល័យ ៦៣,៥% ពិនិត្យមើលប្រវត្តិខ្មែរក្រហម ៤៤,៨% ពិនិត្យយោបល់ជនរងគ្រោះ ២៥% មើលកំណាព្យ ចម្រៀង និងអក្សរសិល្ប៍ និង៤២,៧% នឹង ស្តាប់ ឯកសារសោតទស្សន៍។

ចំណុចទាំងនេះ គ្រាន់តែជាការស្រមៃរបស់ពួកគាត់ ដែលអ្នក ឆ្លើយតបភាគច្រើន មាន ចំណាប់អារម្មណ៍ លើប្រវត្តិខ្មែរក្រហម និងអង្គជំនុំជម្រះវិសាមញ្ញ ដោយធៀបទៅនឹងបញ្ជីមាតិកា។

**តារាងទី ១១ ៖ មាតិកានៅក្នុងវិបផតថលនេះដែលអ្នកអាននឹងស្វែងរក**

| ប្រភេទនៃមាតិកា | អ្នកឆ្លើយតប / ភាគរយ | | |
|---|---|---|---|
| | បាទ / ចាស | ទេ | សរុប |
| អង្គជំនុំជម្រះវិសាមញ្ញ | 60.4% | 39.6% | 100% |
| ស្ថាប័នពាក់ព័ន្ធ | 58.3% | 41.7% | 100% |
| ការគាំទ្រហិរញ្ញវត្ថុ | 33.3% | 66.7% | 100% |
| ឯកសារច្បាប់ | 52.1% | 47.9% | 100% |
| ឯកសារបណ្ណាល័យ | 29.2% | 70.8% | 100% |
| ប្រវត្តិខ្មែរក្រហម | 63.5% | 36.5% | 100% |
| យោបល់ជនរងគ្រោះ | 44.8% | 55.2% | 100% |
| កំណាព្យចម្រៀងនិងអក្សរសិល្ប៍ | 25% | 75% | 100% |
| ឯកសារសោតទស្សន៍ | 42.7% | 57.3% | 100% |

ក្រៅពីគំនិតខាងលើ អនុសាសន៍របស់អ្នកឆ្លើយតប គឺអ្នកឆ្លើយតប (៦៣,៥%) នឹង អាន ព័ត៌មាន ស៊ីជម្រៅ អំពី ប្រវត្តិខ្មែរក្រហម (៦០,៤%) អង្គជំនុំ ជម្រះវិសាមញ្ញ (៥៨,៣%) ស្ថាប័នពាក់ព័ន្ធ និង(៥២,១%) ឯកសារច្បាប់។ ចំណុចនេះ វាស្របគ្នាទៅនឹងអ្នកអានវិបផតថលកាត់ទោសខ្មែរក្រហម (ពួកគេភាគច្រើនចង់អានព័ត៌មានអំពីអង្គជំនុំជម្រះវិសាមញ្ញ និងប្រវត្តិខ្មែរក្រហម)។

បន្ថែមលើនេះទៅទៀត អ្នកមិនទស្សនាវិបផតថល ក៏ប៉ងចង់អានព័ត៌មានទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋាភិបាលរបបខ្មែរក្រហម ហេតុផលអ្វីដែលធ្វើឱ្យខ្មែរក្រហមសម្លាប់មនុស្ស វាលពិឃាត និងឈ្មោះជនរងគ្រោះ មេដឹកនាំនៅតាមតំបន់ផ្សេងគ្នា ដំណើរការកាត់ទោសខ្មែរក្រហម និង ឈ្មោះជន ដែលនឹង ត្រូវ បានកាត់ទោស។ ប្រសិនបើមានលទ្ធភាព អ្នកឆ្លើយតបស្នើគម្រោងវិបផតថលកាត់ទោសខ្មែរក្រហមរកឱ្យឃើញផ្លូវសម្រាប់ឱកាសចូលទស្សនាព័ត៌មានកាត់ទោសខ្មែរក្រហមរបស់អ្នកមិនប្រើប្រាស់អិធើណែត។

**ប្រភេទនៃព័ត៌មានការកាត់ទោសខ្មែរក្រហមនិងអ្នកមើលវិបផតថលមិនទាក់ទងការកាត់ទោសខ្មែរក្រហម**

ជាលទ្ធផល គួរកត់សំគាល់ថា ភាគរយនៃអ្នកឆ្លើយតបដែលមិនពាក់ព័ន្ធនឹងការកាត់ទោសខ្មែរក្រហម និង អ្នកឆ្លើយតបដែលពាក់ព័ន្ធទៅនឹងការកាត់ទោសខ្មែរក្រហម មានការកើនឡើងគួរឱ្យចាប់អារម្មណ៍ នៅ ពេលដែល ពួកគេភាគច្រើនថា មានការចាប់អារម្មណ៍ទៅនឹងបញ្ជីអត្ថបទនៅក្នុងវិបផតថល។ ពួកគេ ចង់អាន ឱ្យស៊ីជម្រៅ អំពី ប្រវត្តិខ្មែរក្រហម និងអង្គជំនុំជម្រះវិសាមញ្ញ ស្ថាប័នពាក់ព័ន្ធ និងឯកសារច្បាប់។ ដូច្នេះ ក្រុមគម្រោងកាត់ទោសខ្មែរក្រហមគួរអភិវឌ្ឍ និងកែលំអអត្ថបទទាំងនេះ ដើម្បីធ្វើឱ្យមានប្រជាប្រិយថែមទៀតទៅលើការកាត់ទោសខ្មែរក្រហម។

**តារាងទី ១២ : បញ្ជីអត្ថបទរបស់វិបផតថលនេះដែលមានសារៈសំខាន់ដល់អ្នកអាន**

| បញ្ជីអត្ថបទ | អ្នកឆ្លើយតប / ភាគរយ | |
|---|---|---|
| | អ្នកឆ្លើយតបមិនពាក់ព័ន្ធការកាត់ទោសខ្មែរក្រហម | អ្នកឆ្លើយតបពាក់ព័ន្ធការកាត់ទោសខ្មែរក្រហម |
| ប្រវត្តិខ្មែរក្រហម | 63.5% | 93.3% |
| អង្គជំនុំជម្រះវិសាមញ្ញ | 60.4% | 93.3% |
| ស្ថាប័នពាក់ព័ន្ធ | 58.3% | 76.7% |
| ឯកសារច្បាប់ | 52.1% | 90.0% |
| សរុប | ***234.3%** | ***353.3%** |

*អ្នកឆ្លើយតបអាចជ្រើសរើសចំលើយច្រើនជាងមួយ

## ៣_សេចក្តីសន្និដ្ឋាននិងអនុសាសន៍

### សន្និដ្ឋាន

វិបផតថលការកាត់ទោសខ្មែរក្រហម នឹងបន្តដំណើរការទៅមុខដោយរលូនខណៈដែលវាទទួលបានការគាំទ្រច្រើន និងទទួលបានប្រជាប្រិយភាពក្នុងចំណោមអ្នកអាន។ វាតែងតែស្ថិតនៅចំណុចកំពូលនៃការស្វែងរកក្នុងម៉ាស៊ីនដែលផ្តល់នូវធនធានព័ត៌មានយ៉ាងសំខាន់ពាក់ព័ន្ធ និងការកាត់ទោសខ្មែរក្រហមនៅកម្ពុជា ពិសេសទាំងអ្នកស្វែងរកព័ត៌មានតាមអិនធើណែតទាំងក្នុង និងក្រៅកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ វិបផតថលនេះគឺមានប្រជាប្រិយ ពិសេសក្នុងចំណោមអ្នកដែលធ្វើការងារជាមួយខ្មែរក្រហម និងការកាត់ទោស។

វិបផតថលនេះ មានរចនាសម្ព័ន្ធមាតិកាយ៉ាងជាក់លាក់មានការរចនាល្អងាយចូលអាន និងមានប្រធានបទ ច្រើន។ វាមានសារៈសំខាន់ និងចាំបាច់ណាស់សម្រាប់អ្នកដែលប៉ងទទួលព័ត៌មានអំពី ការកាត់ទោស ខ្មែរក្រហម។ ទោះបីជាយ៉ាងណា វិបផតថលនេះបានបន្ថែមព័ត៌មាន ដើម្បីបំពេញតម្រូវការអ្នកអាន។ នៅក្នុងរយៈពេលខ្លីនេះវិបផតថលនឹងបន្ត និងផ្សព្វផ្សាយកាន់តែទូលាយ និងបន្ថែមមាតិកាច្រើនថែមទៀត។

### អនុសាសន៍

វិបផតថលនេះគួរ៖

១- ផ្សព្វផ្សាយវិបផតថលដល់សាធារណៈជនដែលពួកគេនឹងចាប់អារម្មណ៍ទៅលើការអានអំពីការកាត់ទោសខ្មែរក្រហម។ ការផ្សព្វផ្សាយតាមរយៈការបោះពុម្ព (ខិតប័ណ្ណ ឬសន្លឹកប័ណ្ណ) វិទ្យុ កាសែត និងទូរទស្សន៍ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតនោះ។

២- វិធីមួយចំនួនផ្សេងទៀតដែលអង្គការមិនមែនរដ្ឋាភិបាលដូចជា វេទិកាទូទៅនៃកម្ពុជា អាចធ្វើការផ្សាយពាណិជ្ជកម្មអំពីវិបផតថលតាមរយៈសិក្ខាសាលា ឬការប្រជុំនានា ដែលពិភាក្សាអំពីប្រធានបទទាក់ទងការ កាត់ទោសខ្មែរក្រហម ដោយសហការ និងមានដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល និង ក្រុមសង្គមស៊ីវិលផ្សេងៗទៀត។

៣- ការដាក់ព័ត៌មានបន្ថែមផ្សេងទៀតទៅក្នុងផ្នែកនីមួយៗ។ បំពេញបន្ថែមព័ត៌មានឱ្យបានច្រើននៅក្នុងអត្ថបទនីមួយៗ។

៤- ផតថលនឹងផ្តល់មាតិកាច្រើនទៀត ដែលត្រូវបានជ្រើសរើសយ៉ាងសម្រិតសម្រាំង ដើម្បីបំពេញតាមតម្រូវការមាតិការបស់អ្នកទស្សនា។

៥- សារព័ត៌មានប្រចាំថ្ងៃ និងការផ្សព្វផ្សាយត្រូវដាក់បន្ថែម និងបង្ហាញនៅក្នុងវិបផតថលឱ្យបានទាន់ពេលវេលា។ ការបន្ថែមមាតិកា គឺជាការចាំបាច់។

៦- ដំណាក់កាលបន្ទាប់នៃគម្រោងវិបផតថលកាត់ទោសខ្មែរក្រហមនេះ និងអាស្រ័យដោយដំណើរការកាត់ក្តី នឹងកាត់ទោសមេដឹកនាំខ្មែរក្រហម គឺវានឹងផ្តល់សារៈសំខាន់ដោយការផ្តល់ព័ត៌មាន ដ៏ច្រើនរបស់វិបផតថលនេះទាក់ទិនដល់អង្គជំនុំជម្រះវិសាមញ្ញនិងប្រវត្តិខ្មែរក្រហម។

៧- វេទិកាទូទៅនៃកម្ពុជា នឹងសហការជាមួយអិនធើណែតកាហ្វេ អង្គការសង្គមស៊ីវិល ដូចជាអង្គការយុវជន ជាឧទាហរណ៍ ដើម្បីផ្តល់លទ្ធភាពដល់អ្នកប៉ងអានព័ត៌មានអំពីខ្មែរក្រហមអាចចូលរកព័ត៌មានបាន តាមរយៈ វិបផតថលនេះ ។ ការត្រៀមរៀបចំនៃកម្មវិធីចូលអិនធើណែតនឹងត្រូវបង្កើតឡើងដំបូងដោយ កិច្ចសហការ ហើយវានឹងក្លាយជាការពិតប្រសិនបើមានការគាំទ្រពីដៃគូអង្គការវេទិកា ទូទៅនៃកម្ពុជា និងអ្នកផ្តល់ជំនួយផងដែរ៕

✍📖✍